# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣*៣៣

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខ: ៣៩៧

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៣

**សាលដីកា**

លេខ: ២៤៤

ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្នី** | ជាប្រធាន |
| ២-លោក | ប្រាក់ | គីមសាន | ជាចៅក្រមរបាយការណ៍ |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រម |

**ក្រឡាបញ្ជី**

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៣៣"ច"ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៣៦ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **រស់ សុខុន** (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរ បុគ្គលិករោងចក្រទឹកកក ទីលំនៅសព្វថ្ងៃភូមិទី៤ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះរស់ ប៉ៅ "ស"ម្តាយឈ្មោះតួ លក្ខណ៍"ស"ប្រពន្ធឈ្មោះរ៉ាន់ ង៉ោ មានកូន០៥នាក់ ។

មានមេធាវី អ្នកស្រី ពីង ធីតា ។

ចុងចម្លើយឈ្មោះ**ជីវ លាក់** ហៅ **ប៉ាវ**(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅភូមិទី៤ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។ ឪពុកឈ្មោះជីវ លីគឹម"ស"ម្តាយឈ្មោះលី ហ្គិច "រ" ប្រពន្ធឈ្មោះជា ហ៊ុយម៉េង មានកូន៣នាក់។

**<u>ចម្ងល់ក្តីរឿង</u>** : ប្តឹងទាមទារសំណងការខូចខាត ជាប្រាក់ ៣៥០០ដុល្លាអាមេរិក .

បានឃើញបណ្តឹងសាទុក្ខលេខ១៤០ ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៣ របស់ឈ្មោះជីវលាក់ ហៅ ប៉ាវ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៣"ច" ចុះថ្ងៃទី២៥-០៣-២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៧ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៣ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១១-១០-២០០១ របស់ឈ្មោះរស់ សុគន្ធ ប្តឹងទាមទារសំណង ការខូចខាតចំនួន៣៥០០ដុល្លាអាមេរិក ពីឈ្មោះជីវ លាក់ ហៅ ប៉ាវ ដោយមូលហេតុថា ផ្ទះរបស់ ខ្លួនមានជញ្ជាំងជាប់គ្នា និងផ្ទះរបស់ជីវ លាក់ ហើយឈ្មោះជីវ លាក់ បាន និងកំពុងសាងសង់ ដោយធ្វេសប្រហែសបណ្តាលឱ្យជញ្ជាំងផ្ទះនោះរលំត្រូវចំផ្ទះបាយដែលសរុបជាប្រាក់នូវទ្រព្យសម្បត្តិ ខូចខាតចំនួន ៣៥០០ដុល្លាអាមេរិក ។

បានឃើញដីកាសំរេចតាមពាក្យសុំលេខ ៩៨៣ ជ.ស ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងសុំរបស់ឈ្មោះរស់ សុគន្ធ ចុះថ្ងៃទី១១-១០-២០០១ ទុក ជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះជីវ លាក់ ហៅប៉ាវ ភេទប្រុស អាយុ៤៨ឆ្នាំ ទីលំនៅនៅភូមិ ៤ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ផ្អាកការសាងសង់ផ្ទះរបស់ខ្លួនជាបន្ទាន់ ដើម្បីរង់ចាំតុលាការធ្វើការសំរេចដល់រឿងអង្គសេចក្តីតាមច្បាប់ ។

៣-ដីកាសំរេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤៤"ក"ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ របស់ តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-បដិសេធពាក្យបណ្តឹង ចុះថ្ងៃទី ១១-១០-២០០១ របស់ដើមចោទឈ្មោះ

រស់ សុគន្ធ ចោលជាអសារបង់ ។

២-ទុកសិទ្ធិឱ្យឈ្មោះ រស់ សុគន្ធ ប្តឹងទាមទារនេះ ពីឈ្មោះ យូ ខុន បានគ្រប់ពេលក្នុងកំណត់ច្បាប់ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី-ពន្ធហ្លឹង១៨០០៛ ប្រាក់ចំណាយកិច្ចការស៊ើបសួរ ៥.០០០៛ និងរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ ។

សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤៤ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះរស់-សុគន្ធ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៤៤"ក" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ របស់តុលាការខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ១ នៃសាលក្រម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៣"ច"ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០-៧-២០០២ របស់ឈ្មោះរស់ សុគន្ធ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៤៤"ក" ចុះថ្ងៃទី២៤-៥-២០០២ របស់តុលាការខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ។

៣-បង្គាប់ឱ្យឈ្មោះជីវ លាក់ ហៅប៉ាវ សងការខូចខាតសំភារៈសំណង់ និងសំភារៈប្រើប្រាស់ជាប្រាក់រៀល ស្មើនិងប្រាក់បាតថៃចំនួន៣១៣២០បាត(បីម៉ឺនមួយពាន់បីរយម្ភៃបាត) និងសំណងថ្លៃការខាតបង់ពេលវេលាក្នុងការរកស៊ី និង ជំងឺចិត្តចំនួន១.០០០.០០០រៀល(មួយលានរៀល) ។ សំណូមពរលើសពីនេះបដិសេធចោល ។

បើគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងដើម្បីធានាសំណង ហើយក្នុងករណីរឹងរូស ត្រូវដាក់គុកបង្ខំរូបកាយទារសំណងតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ៥.០០០៛ និងលើអាជ្ញាធរតុលាការចំនួន ៥.០០០៛ និងបង្គាប់ឱ្យចុងចម្លើយបង់ពន្ធ

សមមាត្រ១៥ លើប្រាក់ដែលត្រូវសង និងជំងឺចិត្ត ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៤០ ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៣ របស់ឈ្មោះជីវលាក់ ហៅ ប៉ាវ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៣"ច" ចុះថ្ងៃទី២៥-០៣-២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះជីវ លាក់ ។

បានឃើញសារណាតបចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះរស់ សុគន្ធ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៣៣"ច" ចុះថ្ងៃទី២៣-៣-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះជីវ លាក់ នាពេលសវនាការថា : ខ្លួនពុំមានលទ្ធភាពសងទេ ពីព្រោះការទាមទារវាខ្ពស់ពេក ។

បានស្តាប់ចម្លើយរបស់ឈ្មោះរស់ សុគន្ធ នាពេលសវនាការថា: ខ្លួនសុំទាមទារឱ្យជីវលាក់ សងការខូចខាត សំណងអគ្គីភ័យ ដែលចុងចម្លើយបង្កឡើង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី ពឹង ធីតា ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា : ខ្លួនសុំឱ្យតុលាការសំរេចសេចក្តី បង្ខំឱ្យចុងចម្លើយ សងសំណងការខូចខាតមកឱ្យកូនក្តីខ្លួន ដូចការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយគូភាគីនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៤០ ចុះថ្ងៃទី២៥-០៣-២០០៣ របស់លោក ជីវលាក់ ហៅប៉ាវ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាម មាត្រា ១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់លោកជីវ លាក់ ក្នុងសារណាចុះថ្ងៃទី២០-១០-២០០២ ថា ខ្លួនបានធ្វើកិច្ចសន្យាម៉ៅការផ្តាច់ ហើយឱ្យមេជាងឈ្មោះ យូ ខុន ទទួលខុសត្រូវការប្រេះស្រាំបាក់បែកដែលបង្កឱ្យប៉ះពាល់ប្រយោជន៍អ្នកជិតខាង នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

. ជញ្ជាំងផ្ទះដែលបាក់ទៅលើផ្ទះរបស់ដើមចោទ ជាផ្ទះរបស់ចុងចម្លើយ ពុំមែនជាផ្ទះរបស់យូ ខុន ឡើយ ។

. រាល់ការអន្តរាយដែលកើតឡើងទៅលើផ្ទះរបស់ដើមចោទពីការបាក់ជញ្ជាំងផ្ទះរបស់ចុងចម្លើយ គឺចុងចម្លើយជាអ្នកទទួលខុសត្រូវ តាមមាត្រា ១២៨ នៃក្រិត្យច្បាប់លេខ ៣៨ ក្រច ចុះថ្ងៃទី២៨-១០-១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យចុងចម្លើយសងសំណងសំភារៈប្រើប្រាស់ដែលខូចខាតចំនួន ១៦.២០០បាត នោះ ពុំមានមូលដ្ឋានច្បាស់លាស់ទេ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣៣"ច" ចុះថ្ងៃទី២៥-០៣-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ហើយ លើកលែងតែសំណងសំភារៈប្រើប្រាស់ចំនួន ១៦.២០០បាត ដែលត្រូវទុកជាមោឃៈ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១-ទទួលបណ្តឹងសាទុក្ខលេខ ១៤០ ចុះថ្ងៃទី ២៥-៣-២០០៣ របស់លោក ជីវ លាក់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៣៣ "ច" ចុះថ្ងៃទី២៥-៣-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែតម្លៃសំភារៈប្រើប្រាស់ចំនួន ១៦.២០០បាត ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៧ ចុះថ្ងៃទី១៥-៩-២០០៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់សំណងខូចខាតសំភារៈប្រើប្រាស់ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រ៛ដែលលោក រស់ សុគន្ធ បានបង់ជួសគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០រៀល ហើយតំរូវឱ្យលោក ជីវ ណាក់ សងប្រាក់ចំនួន៩៥០០៛ ទៅឱ្យលោករស់ សុគន្ធ វិញ ។

បង្គាប់ឱ្យលោក ជីវ ណាក់ បង់ពន្ធសមាមាត្រ លើប្រាក់ដែលត្រូវសងទៅដើមចោទ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ ។